# ទិដ្ឋភាពទូទៅនៃជំងឺផ្លូវចិត្ត

# AN OVERVIEW
# TO
# MENTAL ILLNESSESS

# កែវ សុម្មុនី Keo Somony

- Associate degree of Nursing at CNS
- Bachelor degree of Mental Health Nursing at TSMC
- Master degree of Art in Clinical Psychology and Trauma Treatment at RUPP.
- Ph.D Student at PSBU.
- Official at Department for Mental Health and Substance Abuse, Ministry of Health
- 012/098 476 562
- keosomony@yahoo.com

# នៅចុងបញ្ចប់នៃមេរៀននិស្សិតនឹងអាច

១. អាចរៀបរាប់ពីទស្សនៈទូទៅនៃសុខភាពផ្លូវចិត្ត និងជំងឺផ្លូវចិត្ត
២. អាចពន្យល់ហេតុផលដែលត្រូវយកចិត្តទុកដាក់ពីជំងឺផ្លូវចិត្ត
៣. អាចរៀបរាប់ពីប្រភេទផ្សេងៗនៃជំងឺផ្លូវចិត្ត
៤. អាចរៀបរាប់ពីមូលហេតុនៃជំងឺផ្លូវចិត្ត
៥. អាចរៀបរាប់ពីទំនាក់ទំនងរវាងវប្បធម៌ និងជំងឺផ្លូវចិត្ត

# សុខភាព

សុខភាពជាវត្ថុដ៏មានតំលៃបំផុតសម្រាប់មនុស្សម្នាក់ៗដោយរួមបញ្ចូលគ្នានៃ៖

- សុខភាព ផ្លូវកាយ
- សុខភាព ផ្លូវចិត្ត
- សុខភាព ផ្លូវសង្គម


សុខភាពរាងកាយ
សុខភាពល្អ
សុខភាពផ្លូវចិត្ត
សុខភាពសង្គម

# វត្ថុបំណងទី១

## ទស្សនៈទូទៅនៃសុខភាពផ្លូវចិត្ត និង ជំងឺផ្លូវចិត្ត

# ទស្សនៈទូទៅនៃសុខភាពផ្លូវចិត្ត

សុខភាពផ្លូវចិត្តមានន័យថា៖

- មនុស្សមានអារម្មណ៍ល្អ
- មានសមត្ថភាពគិតគូរបានល្អ
- អាចដោះស្រាយបញ្ហានានាក្នុងជីវិត
- និងអាចបំពេញការងារបានជាប្រក្រតី។


World Health Organization
Mental health
is shaped by more than just the mind.
housing
jobs
inequality
education

# ទស្សនៈទូទៅនៃជំងឺផ្លូវចិត្ត

## ជំងឺផ្លូវចិត្តមានន័យថា៖

- ប៉ះពាល់(ប្រែប្រួល)ទៅលើអារម្មណ៍
- ប៉ះពាល់ (ប្រែប្រួល) ទៅលើអាកប្បកិរិយា

# ទស្សនៈទូទៅនៃជំងឺផ្លូវចិត្ត(ត)

- ប៉ះពាល់ដល់ការគិត (ភាគច្រើនរឿងអវិជ្ជមាន)
- ប្រែប្រួលជំនឿ

➡ ដែលនាំអោយប៉ះពាល់សមត្ថភាព

បំពេញមុខងាររបស់បុគ្គល។

# ទស្សនៈទូទៅនៃសុខភាពផ្លូវចិត្ត និងជំងឺផ្លូវចិត្ត (ត)

- ទោះបីជាយើងនិយាយថាកាយ និងចិត្តហាក់ដូចជាវត្ថុពីរផ្សេងពីគ្នា តាមពិតទៅពួកវាដូចជានៅម្ខាងម្ខាក់នៃកាក់មួយ។
- Even though we talk about the mind and body as if they were separate, in reality they are like two sides of the same coin.

# Three dimensions needs of a person




Thoughts Create Feelings
Feelings Create Behavior
Behavior Reinforces Thoughts

# ទំនាក់ទំនងរវាងខួរក្បាល ចិត្ត និងអារម្មណ៍

បើគ្មានខួរក្បាល មិនមានចិត្ត បើគ្មានចិត្តក៏គ្មានអារម្មណ៍ដែរ



# វត្ថុបំណងទី២

ហេតុផលតម្រូវអោយយកចិត្តទុកដាក់ ចំពោះជំងឺផ្លូវចិត្ត

# វត្ថុបំណងទី២

ហេតុផលតម្រូវអោយយកចិត្តទុកដាក់ ចំពោះជំងឺផ្លូវចិត្ត

# ពីព្រោះ

- វាកើតលើមនុស្សគ្រប់គ្នា
- វាជាបញ្ហាសុខភាពសាធារណៈធ្ងន់ធ្ងរ
- វាមានអសមត្ថភាពខ្ពស់
- សេវាសុខភាពផ្លូវចិត្តមានមិនទាន់គ្រប់គ្រាន់

# ពីព្រោះ....

- សង្គមរស់នៅមានការប្រែប្រួលយ៉ាងខ្លាំង
- ជំងឺផ្លូវចិត្តនាំអោយមានការរើសអើង
- ជំងឺផ្លូវចិត្តអាចព្យាបាលតាមវិធីងាយៗ និងមិនចំណាយប្រាក់ច្រើន

# ពីព្រោះវាកើតលើមនុស្សគ្រប់គ្នា

- គេបានរកឃើញថា ក្នុងចំណោម មនុស្សធំ៥នាក់ មានមួយនាក់បានជួបប្រទះបញ្ហាផ្លូវចិត្តក្នុងជីវិតរស់នៅ
- ប្រការនេះ បង្ហាញអោយឃើញពីសភាពទូទៅនៃការកើតមានបញ្ហាផ្លូវចិត្តដែលមនុស្សម្នាក់ៗជួបប្រទះក្នុងជីវិតរស់នៅ។

# ពីព្រោះវាជាបញ្ហាសុខភាពសាធារណៈធ្ងន់ធ្ងរ

តាមការស្រាវជ្រាវនៅលើពិភពលោកបង្ហាញអោយដឹងថាក្នុងចំណោមមនុស្សធំពេញវ័យដែលមករកសេវាសុខភាពទូទៅ ៤០ភាគរយមានជំងឺផ្លូវចិត្ត ។

# ពីព្រោះវាអសមត្ថភាពខ្ពស់

- ទោះជាមានជំនឿថា ជំងឺផ្លូវចិត្តមិនមានសភាពធ្ងន់ធ្ងរដូចជំងឺផ្លូវកាយ តែវាបានបង្កអោយថមថយនូវសមត្ថភាពដ៏ធ្ងន់ធ្ងរ ហើយវាក៏អាចបង្កអោយស្លាប់មុនជំងឺផ្លូវកាយ ដូចជាដោយសារ អត្តឃាត និងគ្រោះថ្នាក់ផ្សេងៗ
- *មនុស្សខ្លះមានជំងឺផ្លូវកាយនិងជំងឺផ្លូវចិត្តក្នុងពេលជាមួយគ្នា ជំងឺផ្លូវចិត្តធ្វើអោយជំងឺរាងកាយ កាន់តែធ្ងន់ធ្ងរ*
- តាមរបាយការណ៍ ឆ្នាំ ២០០១ បានអោយដឹងថា ក្នុងចំណោមមនុស្ស ១០ នាក់ មានអសមត្ថភាព(ពិការដោយជំងឺផ្លូវកាយ ឬ ជំងឺផ្លូវចិត្ត)ធ្ងន់ធ្ងរ មាន៤នាក់មានជំងឺផ្លូវចិត្ត។

# សេវាសុខភាពផ្លូវចិត្តមានមិនគ្រប់គ្រាន់

នៅប្រទេសជាច្រើន មានការខ្វះខាត:

- Oវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា
- Oអ្នកចិត្តវិទ្យា
- Oអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តជាច្រើនទៀត។ អ្នកជំនាញទាំងនោះត្រូវចំណាយពេលជាច្រើន ដើម្បីព្យាបាលជំងឺផ្លូវចិត្តធ្ងន់ធ្ងរដូចជាជំងឺវិកលចរិត ទោះជាវាមានតិចតួចក៏ដោយ។
- Oជាការល្អ ត្រូវបណ្តុះបណ្តាល គិលានុបដ្ឋាក និងគ្រូពេទ្យទូទៅ អោយចេះពិនិត្យព្យាបាលជំងឺផ្លូវចិត្តទាំងនោះផងដែរ ។

# សង្គមរស់នៅមានការប្រែប្រួលយ៉ាងខ្លាំង

- ប្រទេសជាច្រើននៅលើពិភពលោកកំពុងប្រឈមមុខជាមួយការប្រែប្រួលផ្នែកសេដ្ឋកិច្ច និងសង្គម
- រចនាសម្ពន្ធសហគមន៍កំពុងមានការផ្លាស់ប្តូរដោយសារការអភិវឌ្ឍយ៉ាងរហ័សនិងការលូតលាស់នៃទីក្រុង
- ការផ្លាស់ប្តូរទីកន្លែងរស់នៅពីតំបន់មួយទៅតំបន់មួយ

# សង្គមរស់នៅមានការប្រែប្រួលយ៉ាងខ្លាំង (ត)

- ប្រាក់ចំណូលទាប ការកើនឡើងនៃការគ្មានការងារ
- អំពើហឹង្សាក្នុងសង្គម

➢ បញ្ហាទាំងអស់នេះ គឺជាកត្តាដែលអាចនាំអោយមានបញ្ហាផ្លូវចិត្ត

# ជំងឺផ្លូវចិត្តនាំអោយមានការរើសអើង

- មនុស្សជាច្រើនដែលមានបញ្ហាផ្លូវចិត្ត មិនចង់ទទួលថាខ្លួនមានបញ្ហានេះទេ
- បុគ្គលដែលមានជំងឺផ្លូវចិត្ត ត្រូវទទួលការរើសអើងពីសំណាក់សហគមន៍ និងគ្រួសារ
- ជាងនេះទៀត ពួកគេមិនទទួលបានការព្យាបាលប្រកបដោយក្តីអាណិតអាសូរ ពីអ្នកធ្វើការផ្នែកសុខភាពឡើយ។

# ជំងឺផ្លូវចិត្តអាចព្យាបាលតាមវិធីងាយៗ និងមិនចំណាយប្រាក់ច្រើន

- ការព្យាបាលតាមបែបចិត្តសាស្រ្ត
- ជំងឺផ្លូវចិត្តខ្លះ មិនអាចព្យាបាលអោយជាដាច់បានទេ
- មិនខុសគ្នាពីជំងឺរាងកាយដែរ ជំងឺមហារីក ជំងឺទឹកនោមផ្អែម លើសឈាម និង ជំងឺសន្លាក់...ក៏មិនអាចព្យាបាលអោយជាដាច់ដែរ ។
- ទោះជាជំងឺរាងកាយខ្លះមិនអាចព្យាបាលអោយជាក៏ដោយ តែយើងអាចធ្វើអោយ ជីវិតអ្នកជំងឺទាំងនោះបានប្រសើរដូចគ្នាចំពោះជំងឺផ្លូវចិត្តដែរ។

# វត្ថុបំណងទី៣

## ប្រភេទផ្សេងៗនៃជំងឺផ្លូវចិត្ត

# សំណួរ

តើរោគសញ្ញាចំបងៗ របស់ជំងឺផ្លូវចិត្តមានប៉ុន្មាន?

# រោគសញ្ញាចំបង៥ របស់ជំងឺផ្លូវចិត្ត

## ១.រោគសញ្ញារាងកាយ៖ Somatic Symptoms

វាប៉ះពាល់លើរាងកាយ ដូចជាចុះស្គម និងប៉ះពាល់មុខងាររបស់រាងកាយដូចជា

ការដេកមិនលក់...

## ២.រោគសញ្ញាអារម្មណ៍៖ Emotional Symptoms

ក្រៀមក្រំ ភ័យខ្លាច ព្រួយបារម្ភច្រើន ...

# រោគសញ្ញាចំបង៥ របស់ជំងឺផ្លូវចិត្ត (ត)

## ៣.រោគសញ្ញាការគិត៖ Cognitive Symptoms

រោគសញ្ញាទាំងនេះ ទាក់ទងនឹងការគិត ការយល់ឃើញ របស់អ្នកជំងឺ

ដូចជា គិតចង់ធ្វើអត្តឃាត គិតថាមានអ្នកណាម្នាក់ចង់បង្កទុក្ខទោសដល់ខ្លួន...

# រោគសញ្ញាចំបង៥ របស់ជំងឺផ្លូវចិត្ត (ត)

៤. **រោគសញ្ញា** អាកប្បកិរិយា៖ Behavioral Symptoms

កាច ធ្វើអត្តឃាត ចង់នៅម្នាក់ឯង...

៥. **រោគសញ្ញា**ការទទួលញ្ញាណ៖ Perceptual Symptoms

ការស្តាប់ឮសំលេង ការមើលឃើញអ្វីដែល អ្នកដទៃស្តាប់មិនឮ និងមើលមិនឃើញ

# សំណួរ

តើប្រភេទផ្សេងៗនៃជំងឺផ្លូវចិត្តមានអ្វីខ្លះ?

# ចំលើយ

## ជំងឺផ្លូវចិត្តត្រូវបានចែកជាប្រាំមួយចំណាត់ថ្នាក់ ឬប្រភេទ៖

១.ជំងឺផ្លូវចិត្តដែលកើតមានញឹកញាប់

1.ជំងឺធ្លាក់ទឹកចិត្ត

2.ជំងឺថប់បារម្ភ



# ២.អាកប្បកិរិយាមិនល្អ ញៀនសុរានិងថ្នាំញៀន

- ថ្នាំញៀន



# ២.អាកប្បកិរិយាមិនល្អ ញៀនសុរា និងថ្នាំញៀន (ត)

សុរា



# ៣.បញ្ញា ឬ ជំងឺអាប់បញ្ញា Mental Retardation

- MR វាមិនមែនជាជំងឺផ្លូវចិត្តទេ
- Down Syndrome

ជាសញ្ញាសម្គាល់MR វាប៉ះពាល់

ការលូតលាស់ខួរក្បាលនិងរាងកាយ

ដោយសារបញ្ហាក្រូម៉ូសូម (កើនលើ



# បញ្ញា ឬ ជំងឺអាប់បញ្ញា Mental Retardation

- បញ្ញា ឬ ជំងឺអាប់បញ្ញា ពេលខ្លះគេហៅ ក្នុងន័យយល់បានថា ជាការល្ងូតលាស់យឺតយ៉ាវនៃបញ្ញា ដែលធ្វើអោយកុមារលំបាកក្នុងការរៀនសូត្រ Learning difficulties

- វាកើតឡើងពីវ័យតំបូងនៃជីវិតកុមារ និងបន្តស្ថិតនៅពេញមួយជីវិត
- ក្មេងមានបញ្ញានេះត្រូវបាននាំមកជួបមន្ត្រីសុខាភិបាលពីព្រោះតែ បញ្ហាអនាម័យផ្ទាល់ខ្លួន បញ្ហាអាក្បកិរិយា ដូចជាកាច និងបញ្ហាក្នុងការរៀនសូត្រ ជាដើម

# ៤.ជំងឺផ្លូវចិត្តធ្ងន់ធ្ងរ Severe Mental Disorder

ជំងឺវិកលចរិតរ៉ាំរ៉ៃជាជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ដែលមានអត្រាគ្រោះថ្នាក់១ភាគរយ។វាសំដែងចេញដោយការទទួលញ្ញាណខុស ការជឿខុស ចុះថយការដឹងការពិត ។ វាត្រូវបានប៉ាន់ប្រមាណថាមានដល់ទៅ៨0ភាគរយបណ្តាលពីកត្តាស្នួរពូជ៕

Schizophrenia is a severe mental disorder with a lifetime risk of about 1%, characterized by hallucinations, delusions and cognitive deficits, with heritability estimated at up to 80%.

# ៥.ជំងឺផ្លូវចិត្តមនុស្សចាស់ (65Y UP)

មនុស្សចាស់អាចមានជំងឺផ្លូវចិត្តពីរប្រភេទ៖

- ជំងឺធ្លាក់ទឹកចិត្ត

- ជំងឺវង្វេងស្មារតី

# ៦.ជំងឺផ្លូវចិត្តកុមារ

បញ្ហាផ្លូវចិត្តចំបងដែលកើតលើកុមារមាន៖

- បញ្ហាខួរក្បាលដែលនាំអោយកុមារពិបាករៀនសូត្រ

- សកម្មភាពរពឹសជ្រុល ADHD (Attention Deficit Hyperactivities Disorder)

- បញ្ហាអត្តចរឹត

- ធ្លាក់ទឹកចិត្ត

-នោមដាក់ខោ

# វត្ថុបំណងទី៤

# រៀបរាប់ពីមូលហេតុនៃជំងឺផ្លូវចិត្ត



# សំណួរ

តើកត្តាអ្វីខ្លះដែលបណ្ដាលអោយមានជំងឺផ្លូវចិត្ត?

# កត្តាដែលបណ្ដាលមានជំងឺផ្លូវចិត្ត

- ព្រឹត្តិការណ៍ជីវិតដែលមានភាពតានតឹង
- ប្រវត្តិមិនល្អក្នុងគ្រួសារ
- ជំងឺខួរក្បាល
- លក្ខណៈតំណពូជ
- បញ្ហាវេជ្ជសាស្រ្ត

# ព្រឹត្តិការណ៍ជីវិតដែលមានភាពតានតឹង

- មនុស្សយើងឆ្លងកាត់នូវហេតុការណ៍នានាក្នុងជីវិតហេតុការណ៍មួយចំនួនធ្វើអោយមនុស្សយើងពិបាកចិត្ត និងតានតឹងចិត្ត
- មនុស្សភាគច្រើន បានរៀនវិធីដោះស្រាយហេតុការណ៍ទាំងនោះ ក្នុងជីវិតរបស់ពួកគេ
- នៅពេលដែលមនុស្ស មិនអាចដោះស្រាយឬ ប្រឈមនឹងព្រឹត្តិការណ៍ទាំងនោះបាន ពួកគេនឹងវិវត្តន៍ទៅមានបញ្ហាផ្លូវចិត្ត

# ប្រវត្តិមិនល្អក្នុងគ្រួសារ

មនុស្សដែលឆ្លងកាត់វ័យកុមារភាពប្រកបដោយភាពអាប់អួរ ដោយសារអំពើហឹង្សា ឬខ្វះការគាំទ្រផ្លូវចិត្ត អាចនឹងកើតមានជំងឺផ្លូវចិត្ត នៅពេលធំដឹងក្តី ដូចជា ជំងឺធ្លាក់ទឹកចិត្ត ឬ ជំងឺថប់បារម្ភ



# ជំងឺខួរក្បាល

- វិបត្តិអាប់បញ្ញា
- ជំងឺវង្វេងស្មារតីក្នុងវ័យចាស់
- មានរបួសក្បាលដោយសារជំងឺឆ្កួតជ្រូក
- ជំងឺដាច់សសៃឈាមក្នុងខួរក្បាល (Stroke)
- បំរែបំរួលសារធាតុគីមីក្នុងខួរក្បាល Neurotransmitters

# លក្ខណៈតំណពូជ

- លក្ខណៈតំណពូជ Genetic Factors ជាកត្តាសំខាន់របស់ជំងឺផ្លូវចិត្តធ្ងន់ធ្ងរមួយចំនួន
- ប្រសិនតែឪពុក ឬតែម្តាយមានជំងឺផ្លូវចិត្ត នោះគ្រោះថ្នាក់ដល់កូនមានតិចតួចទេ
- វាដូចគ្នាទៅនឹងជំងឺទឹកនោមផ្អែម និងជំងឺបេះដូងដែរ ដែលវាជំរុញឡើងដោយសារកត្តាបរិយាកាសក្នុងការរស់នៅ។

# បញ្ហាវេជ្ជសាស្ត្រ

- ជំងឺផ្លូវកាយដូចជាការខូចតម្រង់នោមឬជំងឺថ្លើម ពេលខ្លះអាចបង្កអោយមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរបាន
- មនុស្សចាស់ ដែលប្រើថ្នាំច្រើនមុខក្នុងកម្រិតខ្ពស់ អាចនាំអោយមានការវង្វេងវង្វាន់ (Delirium)។


COD
WHAT CAUSES MENTAL ILLNESS ?
HEREDITY
MAY BE PASSED ON FROM PARENTS TO CHILDREN THROUGH GENES.
BIOLOGY
AN ABNORMAL BALANCE OF BRAIN CHEMICAL CALLED NEUROTRANSMITTERS (CHEMICALS HELPING NERVE CELLS COMMUNICATE WITH EACH OTHER)
PSYCHOLOGICAL TRAUMA
TRIGGERED BY PSYCHOLOGICAL TRAUMA SUFFERED AS A CHILD, SUCH AS SEVERE EMOTIONAL,PHYSICAL, OR SEXUAL ABUSE
ENVIRONMENTAL STRESSORS
CERTAIN STRESSORS - SUCH AS DEATH OR DIVORCE, SUBSTANCE ABUSE - CAN TRIGGER A DISORDER IN A PERSON WHO MAY BE AT RISK FOR DEVELOPING A MENTAL ILLNESS.

# វត្ថុបំណងទី៥

# រៀបរាប់ពីវប្បធម៌ និងជំងឺផ្លូវចិត្ត



# វប្បធម៌   និងជំងឺផ្លូវចិត្ត ជាប់ទាក់ទងនឹង

មានហេតុផលខ្លះដែលវប្បធម៌ អាចបណ្តាលអោយមានជំងឺផ្លូវចិត្ត ៖

- ទស្សនៈអំពីជំងឺផ្លូវចិត្ត
- ការប្រើពាក្យរៀបរាប់ពីអារម្មណ៍មួយហ្នង
- ជំនឿអំពីខ្មោច បិសាច និង ព្រលឹង

# ទស្សនៈអំពីជំងឺផ្លូវចិត្ត

- ការយល់ឃើញពីជំងឺផ្លូវចិត្ត មានលក្ខណៈខុសគ្នាទៅតាមវប្បធម៌ផ្សេងៗគ្នា
- ការធ្លាក់ទឹកចិត្ត ការថប់បារម្ភ បញ្ហាគ្រឿងស្រវឹង និងថ្នាំញៀន ដែលជាបញ្ហាផ្លូវចិត្តចំបងនៅផ្នែកពិគ្រោះជំងឺទូទៅ និងនៅក្នុងសហគមន៍ កម្រត្រូវបានគេចាត់ទុកជាជំងឺផ្លូវចិត្តណាស់

# ការប្រើពាក្យរៀបរាប់ពីអារម្មណ៍មួហ្មង
## (Emotional distress)

❖ការពិពណ៌នាអំពីអារម្មណ៍និងជំងឺរបស់មនុស្សម្នាក់ៗ មិនងាយស្រួលក្នុងការបកស្រាយទេ

❖ពាក្យ Depression ប្រែថា ភាពក្រៀមក្រំ អាចប្រើរៀបរាប់ពីអារម្មណ៍និងជំងឺ

❖ភាសាជាច្រើនមានពាក្យប្រាប់ពីអារម្មណ៍ក្រៀមក្រំ តែវាមិនមែនជាពាក្យពណ៌នាពីជំងឺធ្លាក់ទឹកចិត្តទេ

❖យើងត្រូវស្វែងយល់ភាសាប្រើក្នុងតំបន់ ក្នុងការរៀបរាប់ពីអារម្មណ៍ និងជំងឺ

# ជំនឿអំពី ខ្មោច បិសាច និងព្រលឹង

- ជំនឿ ថាមានគេធ្វើអំពើ និងព្រលឹងចូល

  Belief about witchcraft and evil spirits

- មនុស្សនៅក្នុងសង្គមជាច្រើន គិតថាជំងឺរបស់ពួកគេបណ្តាលពី ត្រូវអំពើ និងព្រលឹងបិសាចចូលសណ្ឋិត

  People in many societies feel that their illness  has been caused by witchcraft

# ជំនឿអំពីខ្មោច បិសាច និង ព្រលឹង (ត)

- អាចបណ្ដាលមកពីលទ្ធផលនៃអបិយជំនឿខ្លះ

  The result of some supernatural causes.

- វានឹងទទួលបានផលតិចតួច នៅពេលយើងតតាំងទៅនឹងការជឿទាំងនោះ

  There is little gain from challenging such views

# ការព្យាបាលជំនឿខ្មោចចូល បែបបុរាណខ្មែរ

(2) Somony Keo.mp4



# គ្រូទាយ អាចារ្យ  និងគ្រូពេទ្យឯកទេសវិកលវិទ្យា

- មនុស្សមានជំងឺ តែងតែស្វែងរកការព្យាបាលដោយប្រភពផ្សេងៗ
- មានមនុស្សជាច្រើនភ្ជាប់អារម្មណ៍មិនសប្បាយចិត្តរបស់ពួកគេ ទៅនឹងអបិយជំនឿ ឬកត្តាសង្គម  ដូច្នេះហើយពួកគេស្វែងរកជំនួយពីអ្នកមិនមែនវេជ្ជសាស្ត្រ ដូចជាបែបបុរាណចិន និងបែបមន្តអាគម
- ហេតុផលគេធ្វើបែបនេះដោយសារគេគិតថា ផ្នែកវេជ្ជសាស្ត្រមិនអាចបកស្រាយ ឬព្យាបាលជំងឺគេបានបាន

# គ្រូទាយ  អាចារ្យ  និងគ្រូពេទ្យឯកទេសវិកលវិទ្យា(ត)

- ការព្យាបាលតាមបែបបុរាណ  ប្រហែលជាអាចជួយមនុស្សខ្លះទទួលលទ្ធផលរហ័សជាងការព្យាបាលតាមបែបវេជ្ជសាស្រ្ត
- Traditional treatment may help some people get better quicker than would medical treatment





# ការផ្តល់ប្រឹក្សាដល់មនុស្សមានបញ្ហាផ្លូវចិត្ត

## ការផ្តល់ប្រឹក្សា: counseling

- សង្គមលោកខាងលិច ការផ្តល់ប្រឹក្សាគឺបានជួយអ្នកដែលមានបញ្ហាផ្នែកអារម្មណ៍ ដោយយោងលើទ្រឹស្តីចិត្តវិទ្យាដែលវិវត្តន៍ពីវប្បធម៌របស់ប្រទេសនិមួយៗ
- ដើម្បីអោយការផ្តល់ប្រឹក្សានេះកាន់តែមានសុវត្ថិភាព វាត្រូវអភិវឌ្ឍដោយប្រើវប្បធម៌នៃប្រទេសនីមួយៗ

# ការដកស្រង់ខ្លឹមសារអត្ថបទចេញពីសារណា

- អ្នកព្យាបាលតាមបែបព្រលឹង(បុរាណ)ព្យាបាលទៅលើបញ្ហាផ្នែកអារម្មណ៍ និងការរអ៊ូរទាំផ្នែកអាកប្បកិរិយាបានប្រសើរជាងអ្នកជំនាញវិជ្ជាជីវៈ( Dr.Ok Vannika សារណា )។
- The spirits healer did better on mood and behavioral complaints, than the professional therapist did.

# ឯកសារសំអាង

- ទីណាគ្មានវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា
- Where there is no Psychiatrist pages 3-29
- The others sources, FB, You tube…